# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុងពិធីបើកសិក្ខាសាលាជាតិ
# ស្តីពី
# ការរៀបចំផែនការសកម្មភាព និង ថវិកា ឆ្នាំ ២០១៩ របស់ គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៨

- **ឯកឧត្តមរដ្ឋមន្ត្រី និង ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ;**
- **ឯកឧត្តមប្រធានក្រុមប្រឹក្សា និង ឯកឧត្តម, លោកជំទាវ, អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត;**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាទីមេត្រី!**

ថ្ងៃនេះ, ខ្ញុំមានក្តីរីករាយ ដោយបានចូលរួមជាអធិបតីក្នុងពិធីបើក **សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និង ថវិកា ឆ្នាំ ២០១៩ របស់ គ.ជ.អ.ប** នាពេលនេះ ។ ក្នុងនាម គ.ជ.អ.ប និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីអញ្ជើញចូលរួមសិក្ខាសាលាជាតិ ដែលនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃនេះ ។

នេះជាការជួបជុំគ្នាដ៏មានសារៈសំខាន់ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និង បញ្ហាប្រឈមនានានៃការអនុវត្តផែនការសកម្មភាព និង ថវិកាឆ្នាំ ២០១៨ របស់ គ.ជ.អ.ប និង ដើម្បីផ្តល់ឱកាសឱ្យមានការពិភាក្សា និង ពិគ្រោះយោបល់ ក្នុងចំណោមតួអង្គពាក់ព័ន្ធនានា, ទាំងនៅថ្នាក់ជាតិ និង នៅថ្នាក់ក្រោមជាតិ, ដើម្បីរិះរកដំណោះស្រាយចំពោះបញ្ហាប្រឈម និង ស្វែងរកការឯកភាពគ្នាលើសេចក្តីព្រាង

ផែនការសកម្មភាព និង ថវិកាឆ្នាំ ២០១៩ របស់ គ.ជ.អ.ប ដើម្បីឈានទៅរៀបចំបញ្ចប់ និង ដាក់ជូន គ.ជ.អ.ប ពិនិត្យ និង សម្រេច ។

ផ្អែកតាមកម្មវិធីដែលបានគ្រោងទុក សម្រាប់រយៈពេលពីរថ្ងៃខាងមុខនេះ អង្គសិក្ខា-សាលាជាតិទាំងមូលនឹងបង្ហាញអំពីវឌ្ឍនភាព និង បញ្ហាប្រឈមនានា នៅក្នុងការអនុវត្ត ក្នុងឆ្នាំ ២០១៨ និង អំពីសេចក្តីព្រាងសកម្មភាពជាអាទិភាពនានា ដែលយើងគ្រោងនឹងសម្រេចឱ្យបាននៅក្នុងឆ្នាំ ២០១៩ ខាងមុខនេះ ។ សកម្មភាពជាអាទិភាពទាំងនេះ ត្រូវបានគ្រោងឡើង ដោយមានការជជែកពិភាក្សាគ្នាជាបឋម ជាមួយតំណាងស្ថាប័នអនុវត្តនានា តាំងពីប៉ុន្មានខែកន្លងមក ដោយផ្អែកជាសំខាន់ទៅលើផែនការអនុវត្ត ៣ ឆ្នាំ ដំណាក់កាលទី ៣ នៃកម្មវិធីជាតិរយៈពេល ១០ ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ ជាមួយគ្នានេះដែរ, សកម្មភាពទាំងនេះ ក៏ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើគម្រោងថវិកាសរុបប្រមាណ **២ ៤០៨ ៩៩១ លានរៀល** សមមូលនឹង **៥៩៥ លានដុល្លារអាមេរិក** រួមបញ្ចូលនូវ៖ (១)-ថវិការដ្ឋចំនួនប្រមាណ **២ ២៣១ ៤៤១ លានរៀល** សមមូលនឹង **៥៥១ លានដុល្លារអាមេរិក** ដែលក្នុងនោះ មានថវិកាចំនួនប្រមាណ **២ ១៩៩ ៦៣៦ លានរៀល** សមមូលនឹង **៥៤៣ លានដុល្លារអាមេរិក** សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ, និង (២)-ថវិកាចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ចំនួនប្រមាណ **១៧៧ ៥៥០ លានរៀល** សមមូលនឹង **៤៤ លានដុល្លារអាមេរិក** ។ បើប្រៀបធៀបនឹងឆ្នាំ ២០១៨, ថវិការបស់រដ្ឋបាលថ្នាក់-ក្រោមជាតិឆ្នាំ ២០១៩ ខាងមុខនេះ មានការកើនឡើងប្រមាណជិត **៥១៤ ៩៦២ លានរៀល** សមមូលនឹង **១២៧ លានដុល្លារអាមេរិក** ដោយសារកំណើនសេដ្ឋកិច្ចជាតិ, ការបង្កើនអត្រាចូលរួមរបស់ថវិការដ្ឋទៅក្នុងមូលនិធិឃុំ/សង្កាត់, មូលនិធិក្រុង/ស្រុក, និង ការបង្កើតឱ្យមាននូវប្រភពចំណូលផ្សេងៗទៀត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្ញុំនឹងគូសបញ្ជាក់បន្ថែម នាពេលបន្តិចទៀតនេះ ។ យ៉ាងណាមិញ, ចំនួនថវិកានេះ នៅពុំទាន់បានគិតបញ្ចូលនូវថវិកាដែលត្រូវផ្ទេរដោយមានលក្ខខណ្ឌ សម្រាប់អនុវត្តមុខងារនានារបស់ក្រសួងមួយចំនួន ដែលបានសម្រេចចិត្តផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ ។ ជាមួយគ្នានេះ, អង្គសិក្ខាសាលាក៏នឹងបានស្តាប់នូវបទបង្ហាញរបស់តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អំពីការបែងចែកថវិកាទាំងនេះ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

នៅពេលរសៀលថ្ងៃស្អែក, អង្គសិក្ខាសាលានឹងបានស្តាប់នូវសារនយោបាយជាគន្លឹះ

ស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.អ.ប** នៅក្នុងពិធីបិទសិក្ខាសាលានេះ ។ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្នុងនាម គ.ជ.អ.ប, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ដែលបានចូលរួមចំណែកក្នុងការសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើនក្នុងអាណត្តិទី ៥ នៃរាជរដ្ឋាភិបាល ពិសេស ក្នុងឆ្នាំ ២០១៨ នេះ ពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល មានជាអាទិ៍៖ ការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការកែទម្រង់រដ្ឋបាលសាធារណៈ ។ ជាការពិត, កិច្ចការកែទម្រង់ទាំងបីការដ្ឋាននេះ នឹងបន្តតួនាទីជាសសរស្តម្ភគន្លឹះ សម្រាប់ធានាជោគជ័យនៃការអនុវត្តកម្មវិធីនយោបាយ និង **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៦ នេះ ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះដែរ, ខ្ញុំសូមជម្រាបជូនអង្គសិក្ខាសាលាអំពីការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដែលជាសកម្មភាពដ៏សំខាន់មួយនៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី ៣ (CAP3) នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានចាប់ផ្តើមអនុវត្ត ពីឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០២០ ដោយបានផ្តោតជាចម្បងលើការផ្សារភ្ជាប់គ្នារវាងថវិកាទៅនឹងគោលនយោបាយ ដូចខាងក្រោម៖

**ទី ១**-យើងបាន និង កំពុងពិនិត្យមើលឡើងវិញ និង អនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ សម្រាប់រយៈពេលមធ្យម និង រយៈពេលវែង ។ ពាក់ព័ន្ធនឹងគោលនយោបាយនេះ, យើងបានកំណត់យ៉ាងច្បាស់លាស់អំពីការបង្កើតយន្តការមួយចំនួន រួមមាន៖ មូលនិធិក្រុង/ស្រុក, មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ, ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ, និង ការរៀបចំឱ្យមានប្រភពចំណូលផ្ទាល់របស់រដ្ឋបាលក្រុង/ស្រុក ។ ក្នុងក្របខ័ណ្ឌនៃមូលនិធិឃុំ/សង្កាត់ ដែលត្រូវបានបង្កើតឡើងជាង ១៥ ឆ្នាំ កន្លងមកនេះ និង ក្នុងក្របខ័ណ្ឌនៃមូលនិធិក្រុង/ស្រុក ដែលត្រូវបានបង្កើតឡើងរយៈពេល ៦ ឆ្នាំកន្លងមកនេះ, យើងបានពិនិត្យមើលឡើងវិញអំពីចំណាយផ្នែករដ្ឋបាល ដើម្បីធានាដល់ការបង្កើនធនធានសម្រាប់ផ្នែកអភិវឌ្ឍន៍ ដោយបានបង្កើននូវចំនួនភាគរយនៃការវិភាជពីថវិការដ្ឋ ទៅឱ្យមូលនិធិទាំងនេះ ដើម្បីធានាថា រដ្ឋបាលឃុំ/សង្កាត់ និង រដ្ឋបាលក្រុង/ស្រុកនីមួយៗ នឹងកាន់តែមានធនធាន

និង លទ្ធភាពសមស្រប ក្នុងការបំពេញនូវអាណត្តិរបស់ខ្លួន ក្នុងនាមជាតំណាងដែលត្រូវបាន ប្រជាពលរដ្ឋបោះឆ្នោតផ្តល់ការទុកចិត្ត ។

**ទី ២-** នៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យើងបានដាក់ឱ្យអនុវត្តនូវយន្តការចែករំលែកចំណូលពន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកន្លងមក យន្តការនេះត្រូវបានអនុវត្តតែនៅរដ្ឋបាលរាជធានី-ខេត្តប៉ុណ្ណោះ ។ ពាក់ព័ន្ធនឹងបញ្ហានេះ, យើងបានធ្វើការកែសម្រួល និង បានអនុញ្ញាតឱ្យរដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និង ឃុំ/សង្កាត់នានា ទទួលបាននូវចំណូលបន្ថែមពីការចែករំលែកលើការប្រមូលពន្ធ ដែលជាគុណប្រយោជន៍ថវិការាជធានី-ខេត្ត ។ បន្ថែមលើនេះ, យើងគ្រោងនឹងពិនិត្យមើលឡើងវិញ លើយន្តការនេះ ដើម្បីធានាឱ្យការចែករំលែកចំណូលពន្ធ រវាងរដ្ឋបាលនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តប្រកបដោយសមធម៌ ស្របតាមទំហំការងារ, តួនាទី និង ភារកិច្ចរបស់ថ្នាក់-រដ្ឋបាលនីមួយៗ ។

**ទី ៣-** ចាប់ពីឆ្នាំ ២០១៧ មក, យើងបានដាក់ឱ្យអនុវត្តនូវយន្តការវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលស្រុកមួយចំនួនដែលមានលក្ខណៈសម្បត្តិសមស្រប; ហើយនៅឆ្នាំ ២០១៩ ខាងមុខ, យើងនឹងដាក់ឱ្យអនុវត្តយន្តការនេះ សម្រាប់រដ្ឋបាលក្រុង និង រដ្ឋបាលខណ្ឌមួយចំនួនបន្ថែមទៀត ដើម្បីគាំទ្រដល់គម្រោងអភិវឌ្ឍន៍មួយចំនួនរបស់រដ្ឋបាលទាំងនោះ ។ ប្រភពហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគរបស់រដ្ឋបាលស្រុក/ក្រុង/ខណ្ឌនៅឆ្នាំ ២០១៩ នឹងមានប្រភពពីថវិកាជាតិ និង កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

**ទី ៤-**ផ្អែកលើផែនការសកម្មភាពរួមដំណាក់កាលទី ៣ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យើងបានរៀបចំសេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ដាក់ឱ្យអនុវត្តនូវការរៀបចំថវិកាកម្មវិធី នៅក្នុងខេត្តចំនួន ១២ នៅក្នុងឆ្នាំ ២០១៨ នេះ ហើយនឹងបង្កើនដល់រាជធានី-ខេត្តចំនួន ១៨ នៅឆ្នាំ ២០១៩ ខាងមុខ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ទន្ទឹមនឹងសមិទ្ធផលដូចបានគូសបញ្ជាក់ខាងលើ, យើងនៅមានបញ្ហាប្រឈមមួយ-ចំនួនដែលត្រូវដោះស្រាយ ដើម្បីសម្រេចបាននូវគោលបំណងនៃការអនុវត្តគោលនយោបាយ

វិមជ្ឈការហិរញ្ញវត្ថុ ។ នៅក្នុងបរិការណ៍នេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានកំណត់នូវកិច្ចការអាទិភាពមួយចំនួនសម្រាប់ឆ្នាំ ២០១៩ ខាងមុខ រួមមាន៖

**ទី ១**-យើងនឹងខិតខំប្រឹងប្រែង និង ពិនិត្យលើធនធានពីប្រភពផ្សេងៗទៀត ដើម្បីបង្កើនទំហំធនធានថវិកាឃុំ/សង្កាត់ សម្រាប់អភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនឱ្យបានសមស្រប ចាប់ពីឆ្នាំ ២០២០ តទៅ ដើម្បីឱ្យឃុំ/សង្កាត់ មានលទ្ធភាពភាពអាចឆ្លើយតបបានសមស្របទៅនឹងតម្រូវការជាក់ស្តែង និង ជាអាទិភាពនៅមូលដ្ឋាន ។

**ទី ២**-យើងនឹងខិតខំរៀបចំបញ្ចប់នូវសេចក្តីព្រាង និង ដាក់ឱ្យប្រើប្រាស់នូវឯកសារ **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៨-២០២៥** ដែលផែនការយុទ្ធសាស្ត្រនេះ នឹងមានសង្គតិភាពជាមួយនឹង**ផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាជាតិឆ្នាំ ២០១៨-២០២៥** ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយរាជរដ្ឋាភិបាល តាំងពីខែមករា ឆ្នាំ ២០១៨ កន្លងមក ។

**ទី ៣**-ក្នុងបរិការណ៍នៃការប្រែប្រួលចំពោះការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និង ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ទៅលើការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ក្នុងកម្មវិធីកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានណែនាំ និង អនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការគ្រោងកញ្ចប់ថវិកាសម្រាប់គាំទ្រដល់ផែនការសកម្មភាពប្រចាំឆ្នាំ ស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិសាមីពាក់ព័ន្ធ ។

**ទី ៤**-ដើម្បីធានាដល់ការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និង មានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធនៅក្នុងអាណត្តិទី ៦ នៃរាជរដ្ឋាភិបាលនេះ, លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង ៣ ត្រូវបន្តសហការគ្នាឱ្យកាន់តែជិតស្និទ្ធ ដើម្បីធានាបាននូវការឯកភាពគ្នា ក្នុងក្របខណ្ឌទស្សនវិស័យរួម ប្រកបដោយភាពច្បាស់លាស់មួយ សំដៅដោះស្រាយបញ្ហាប្រឈមនានា ។ លេខាធិការដ្ឋាននៃកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមជាប់ជាប្រចាំក្នុងកិច្ចសហប្រតិបត្តិការ នៅក្នុងក្របខណ្ឌនៃយន្តការសម្របសម្រួលនេះផងដែរ ។

**ទី ៥**-ជាចំណុចចុងក្រោយ តែអាចសំខាន់ជាងគេ, គឺ ការខិតខំពង្រឹងសមត្ថភាពស្ថាប័ន និង សមត្ថភាពបុគ្គលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានា ដើម្បីលើកកម្ពស់ការបំពេញការងារប្រកបដោយការទទួលខុសត្រូវ និង សីលធម៌វិជ្ជាជីវៈ ព្រមទាំងធានាបាននូវតម្លៃនៃប្រាក់ (Value for money) ។ ធនធានថវិកាដែលផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ហើយចំណាយនានាត្រូវផ្អែកលើលិខិតបទដ្ឋាន និង វិធាននានានៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលត្រូវបានកំណត់ដាក់លាក់ ។ ជាការពិតណាស់, យើងម្នាក់ៗត្រូវមានការទទួលខុសត្រូវ ក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈ ឱ្យបានត្រឹមត្រូវ និង មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ ក្នុងស្មារតីនេះ, នៅឆ្នាំ ២០១៩ ខាងមុខ, យើងក៏នឹងពិនិត្យមើលឡើងវិញ និង បន្តពង្រឹងនូវការអនុវត្តប្រព័ន្ធអធិការកិច្ច និង សវនកម្មលើការអនុវត្តនីតិវិធីនានានៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមថ្លែងអំណរគុណចំពោះ គ.ជ.អ.ប. ដែលបានផ្តល់វេទិកានេះឱ្យខ្ញុំ ជម្រាបជូនអំពីវឌ្ឍភាពនៃកំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុ និង ទិសដៅការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងផ្នែកនេះ ។ ដូចខ្ញុំបានបញ្ជាក់ពីខាងដើមហើយថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានតាំងចិត្តក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានធនធានសមស្របសម្រាប់លើកកម្ពស់, ទាំងការអភិវឌ្ឍមូលដ្ឋាន និង ទាំងការផ្តល់សេវាសាធារណៈចាំបាច់នានា, ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព ។

ខ្ញុំសូមឆ្លៀតឱកាសនេះ សម្តែងនូវអំណរគុណចំពោះការបន្តគាំទ្រ, ទាំងជាជំនួយផ្នែកហិរញ្ញវត្ថុ និង ជំនួយផ្នែកបច្ចេកទេស ពីសំណាក់ដៃគូអភិវឌ្ឍន៍នានា ដល់ការអភិវឌ្ឍលើគ្រប់វិស័យ និង កិច្ចដំណើរការកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ពិសេសនៅក្នុងការដ្ឋាននៃការកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, ការកែទម្រង់រដ្ឋបាលសាធារណៈ, និង ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ខ្ញុំក៏សូមអរគុណដល់ការចូលរួមចំណែកក្នុងភាពជាដៃគូដ៏សំខាន់ និង ប្រកបដោយលក្ខណៈស្ថាបនា របស់អង្គការសង្គមស៊ីវិលនានានៅក្នុងការបំពេញការងាររបស់រាជរដ្ឋាភិបាលផងដែរ ។

មុននឹងបញ្ចប់, ក្នុងនាមរាជរដ្ឋាភិបាល និង គ.ជ.អ.ប, ខ្ញុំសូមសម្តែងនូវជំនឿយ៉ាងមុតមាំលើការចូលរួមផ្តល់យោបល់ដ៏មានតម្លៃរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី នៅក្នុងការរៀបចំផែនការសកម្មភាព និង ថវិកាឆ្នាំ ២០១៩ របស់ គ.ជ.អ.ប ហើយខ្ញុំសង្ឃឹមថា សិក្ខាសាលាជាតិនេះ នឹងទទួលបានលទ្ធផលជាផ្លែផ្កាតាមគោលដៅដែលបានគ្រោងទុក ។

ជាទីបញ្ចប់, ក្នុងឱកាសចូលឆ្នាំសកលដែលនឹងមកដល់ក្នុងពេលឆាប់ៗខាងមុខនេះ, ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរ ជូនចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំង-អស់, សូមប្រកបដោយសុខភាពល្អបរិបូរណ៍, វិបុលភាព និង សម្រេចបានជោគជ័យគ្រប់ភារកិច្ច ។ ខ្ញុំសូមប្រកាសបើក **សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និង ថវិកាឆ្នាំ ២០១៩ របស់ គ.ជ.អ.ប** ចាប់ពីពេលនេះតទៅ ។

***សូមអរគុណ !***